# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ..៧៧.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធី ក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

**មាត្រា១.-**

បង្កើតគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធី ក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ ដែលមានសមាសភាព ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម បណ្ឌិត | **ហេង វង្សប៊ុនឆាត** | ទីប្រឹក្សារាជរដ្ឋាភិបាល | **ប្រធាន** |
| ២- ឯកឧត្តម បណ្ឌិត | **អ៊ុន ទីវជាតិ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | **អនុប្រធាន** |
| ៣-ឯកឧត្តម បណ្ឌិត | **ឆយ អួន** | សមាជិក គ.ទ.ក. និង ក.ស.វ. | **អនុប្រធាន** |
| ៤- ឯកឧត្តម បណ្ឌិត | **ស៊ុន សំណាង** | | **អនុប្រធាន** |
| ៥- ឯកឧត្តម បណ្ឌិតរដ្ឋ | **តិច សំណាង** | អគ្គលេខាធិការ គ.ទ.ក. | **អនុប្រធានអចិន្ត្រៃយ៍** |
| ៦- ឯកឧត្តម បណ្ឌិត | **ស៊ិន ម៉េងស្រ៊ុន** | សមាជិក ក.ស.វ. | **សមាជិក** |
| ៧- ឯកឧត្តម បណ្ឌិត | **ហង់ ជួនណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | **សមាជិក** |
| ៨- លោកជំទាវ បណ្ឌិត | **បូ ជុំស៊ិន** | | **សមាជិក** |
| ៩- ឯកឧត្តម បណ្ឌិត | **ចាប ស៊ុថារិទ្ធិ** | នាយកខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ | **សមាជិក** |
| ១០- ឯកឧត្តម បណ្ឌិត | **គីម រ័ត្នវិសិដ្ឋ** | នាយកខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន | **សមាជិក**✓ |
| ១១- ឯកឧត្តម បណ្ឌិត | **ឃី ផាន់រ៉ា** | សមាជិក ក.ស.វ. | **សមាជិក** |
| ១២- ឯកឧត្តម បណ្ឌិត | **រស់ ចន្ទ្រាបុត្រ** | | **សមាជិក** |
| ១៣- ឯកឧត្តម បណ្ឌិត | **ប៉ាំ ថាវ័ន** | អគ្គនាយកឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា | **សមាជិក** |
| ១៤- ឯកឧត្តម បណ្ឌិត | **អ៊ុំ សុផល** | សាកលវិទ្យាធិការ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | **សមាជិក** |
| ១៥- ឯកឧត្តម បណ្ឌិត | **ចំន្ទ សំណព្វ** | អនុប្រធានវិទ្យាស្ថានភាសាជាតិ | **សមាជិក** |
| ១៦- ឯកឧត្តម បណ្ឌិត | **ស៊ី ឈុំប៊ុន** | អគ្គលេខាធិការរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ១៧- លោក បណ្ឌិត | **សុខ ទូច** | អនុប្រធានវិទ្យាស្ថានទំនាក់ទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ១៨- លោក បណ្ឌិត | **សុខ ឧត្តរា** | មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ទ.ក. | **សមាជិកអចិន្ត្រៃយ៍** |

**មាត្រា២.-**

គណៈកម្មការជាតិមានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំគោលការណ៍ និងនីតិវិធី ក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទថ្នាក់ក្រោយឧត្តមសិក្សា
- លើកសំណើជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច និង
- ទទួលភារកិច្ចមួយចំនួនទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល ។

**មាត្រា៣.-**

ថវិកាសម្រាប់ធានាដំណើរការនិងការប្រជុំនានាក្នុងគណៈកម្មការជាតិ ជាថវិកាជាតិតាមគម្រោងដែលស្នើឡើងដោយគណៈកម្មការជាតិ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៤.-**

សមាជិកគណៈកម្មការជាតិត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធាន ឬ អនុប្រធានអចិន្ត្រៃយ៍ មានតួនាទីជាប្រធានស្តីទី ។

**មាត្រា៥.-**

គណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធី ក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ យកអគ្គលេខាធិការដ្ឋាន គ.ទ.ក. ជាសេនាធិការ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ